# រោគសញ្ញានៃជំងឺផ្លូវចិត្ត

**រោគសញ្ញាចំពោះអារម្មណ៍និងចិត្ត**

- មានអារម្មណ៍អស់សង្ឃឹមឬបាត់បង់ជំនួយ - អារម្មណ៍ទុក្ខព្រួយហាក់ដូចជាគ្មានអ្វីនៅក្នុងខ្លួនឬមានសភាពភ្លឹកៗ
- មានអារម្មណ៍ចង់ប្រព្រឹត្តិបទល្មើសផ្សេងៗ ឡប់ៗឬចេះតែមានការសង្ស័យនេះសង្ស័យនោះ
- មិនសប្បាយក្នុងចិត្ត - បាត់បង់នូវអារម្មណ៍កំសាន្តរីករាយ
- ចង់យំបន្តិច - ចង់សើចបន្តិច
- មានអារម្មណ៍ភ័យខ្លាចឬទុក្ខព្រួយដោយឥតហេតុផល - ឬមានអារម្មណ៍មិនស្រួលយ៉ាងខ្លាំងនៅក្នុងខ្លួន
- ឧស្សាហ៏មានអារម្មណ៍ឡើងចុះយ៉ាងខ្លាំង - យោលយោគមិននឹងន់
- មានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំងក្នុងគ្រួសារ ឬការដែលគ្មានការរាប់រកពីមិត្តភ័ក្តឬអ្នកដែលមានវ័យដូចគ្នា-មានអារម្មណ៍ខ្មាស់អៀនច្រើនហួសប្រមាន

**រោគសញ្ញាចំពោះការគិតនិងការនិយាយ**

- គិតតែពីរឿងធ្វើអត្តឃាត - និយាយតែពីរឿងធ្វើអត្តឃាត
- មានបញ្ហាចំពោះស្មារតី - មានការភ្លេចភ្លាំងច្រើន
- មានគំនិតមិនចង់ធ្វើអ្វីទាំងអស់ ឬគ្មានការជឿជាក់ - និយាយជ្រាំដែលៗ
- ព្រួយបារម្មណ៏ច្រើនអំពីសុខភាព ការងារ ប្រាក់កាស គ្រួសារ ឬហេតុការណ៏តាមផ្លូវជាដើម
- គិតពីអ្នកដែលត្រូវបានអ្នកផ្សេងទៀតតាមឃ្លាំមើលឬកាត់ទោស - មានគំនិតមិនប្រក្រតី
- មិនទទួលយកបញ្ហាដែលពិត - មិនអើពើសកម្មភាពប្រចាំថ្ងៃ
- មានគំនិតមិនយល់ស្រប - ភាន់ភាំងឬមមើលមមាយ
- សំណើចមិនសមរម្យ - ពោលពាក្យដោយគ្មានការគិតឬវិចារណញ្ញាណ
- ប្រើពាក្យឬភាសាប្លែកៗ - និយាយពីរឿងប្លែកៗ

**រោគសញ្ញាចំពោះអាកប្បកិរិយានិងសកម្មភាព**

- ដកខ្លួនចេញពីអ្នកផ្សេងៗ - ក្លាយជាជនឯកោ
- ធ្វើទុក្ខទោសខ្លួនឯង - វាយតប់ឬដុតខ្លួនឯង
- អន្ទះអន្ទែងខ្លាំង - ក្លាយជាមនុស្សឆាប់ឆេវឆាវមានចិត្តស្រាល
- ភ្លែតចុះភ្លែតឡើង អាកប្បកិរិយារហ័សរហួន- ធ្វើតំណើរទៅត្រង់នេះបន្តិចត្រង់នោះបន្តិចយ៉ាងរហ័ស
- មានបញ្ហាចំពោះដំណេក - ដេកច្រើន - ប្រែប្រួលដំណេកខុសពីប្រក្រតី
- ចូលចិត្តសុរាឬគ្រឿងញៀនផ្សេងៗ - ផ្តេកផ្តួលលើរសជាតិរបស់វា
- ប្តូរទំលាប់របស់ខ្លួន - បោះបង់ភាពអនាម័យរបស់ខ្លួន
- ទង្វើជ្រាំដែលៗ - មិនធ្វើមិនបាន
- បញ្ឈប់សកម្មភាពការងារប្រចាំថ្ងៃ - លែងរវល់ពីរឿងជីវភាព
- បញ្ចេញនូវអាកប្បកិរិយាប្លែកៗ - រឹឫកពាប្លែកៗ
- ចង់រត់គេចចេញ - ប្តូរកន្លែងយ៉ាងញឹកញាប់ - ឬប្តូរទីលំនៅ

**រោគសញ្ញាចំពោះសរីរាង្គនិងរាងកាយ**

- មានអារម្មណ៍អស់កំលាំងយ៉ាងខ្លាំង - បាត់បង់ថាមពល
- បាយមិនបាន - បាយបានច្រើនហើយឡើងទំងន់
- មានជំងឺលើរាងកាយយ៉ាងច្រើនដែលពិបាកនឹងរៀបរាប់អោយយល់បាន - មានអាការៈឈឺក្បាលជាដើម
- ឧស្សាហ៏វិលមុខ - សំបូរជាតិផ្អែមក្នុងខ្លួន - ពិបាកលេបអាហារ
- មានសភាពភ័យញ័រខ្លាំង - មុខឡើងក្រហមដោយឥតហេតុផល - ឧស្សាហ៏សន្លប់ភ្លាមៗ